■ គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា [SCCRP]
[ការផ្តល់ជូនរបស់ AFD - CKH-១០០៧-០១-S និង CKH-១០៧៧-០២-T]
AFD

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)

ករណីសិក្សាលេខ ៤

# ក្រុមលក់ស្រូវអង្ករនៃសហគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍

ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១៨

អ្នកនិពន្ធ៖ ហ៊ី ធី (GRET)[១]

GRET Professionals for fair development

មាតិកា

១. ទិដ្ឋភាពទូទៅ៖ សេចក្តីសង្ខេបនៃបទពិសោធន៍របស់ក្រុមលក់ស្រូវអង្ករនៅក្នុង FWUC បារាយណ៍ ..................២
២. ដើមកំណើតនៃសកម្មភាព និងការចូលរួមរបស់ភាគីពាក់ព័ន្ធ..................................................៣
៣. ដំណើរការនៃការអនុវត្ត.........................................................................................៤
៤. លទ្ធផលនៃប្រតិបត្តិការ .........................................................................................៦
៥. ការវិភាគសេដ្ឋកិច្ច ..............................................................................................៧
៦. លទ្ធភាព៖ ភាពខ្លាំង ភាពខ្សោយ និងការមើលទុកនាពេលអនាគតនៃការផ្តួចផ្តើមនេះ...................................៩
៧. លទ្ធភាពពង្រីក និងលក្ខខណ្ឌសម្រាប់ការពង្រីកដោយមិនមានការគាំទ្រពីគម្រោង SCCRP .......................១២

អក្សរកាត់

| | | | |
|---|---|---|---|
| AFD | *ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង* | ISC | មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ |
| FO | អង្គការកសិករ | SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| FWN | បណ្តាញកសិករ និងទឹក | SCCRP | គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា |
| FWUC | សហគមន៍កសិករប្រើប្រាស់ទឹក | | |
| GRET | *ក្រុមស្រាវជ្រាវ និងផ្លាស់ប្តូរបច្ចេកវិទ្យា* | | |

សេចក្តីបដិសេធ៖ ឯកសារនេះបង្ហាញតែពីទស្សនៈរបស់អ្នកនិពន្ធប៉ុណ្ណោះ ពុំមែនជាទស្សនៈរបស់ AFD ឬ SNEC ឡើយ។



[១] www.gret.org

ខ្នាត និងមាត្រដ្ឋាន

| | |
|---|---|
| ha | ហិកតា |
| kg | គីឡូក្រាម |
| KHR | ប្រាក់រៀលខ្មែរ (ប្រហែលជា ៤,០០០ រៀកសម្រាប់ ១ ដុល្លារ)។ |
| t | តោន (១ តោន ស្មើ ១០០០ គីឡូក្រាម) |
| USD | ប្រាក់ដុល្លារសហរដ្ឋអាមេរិក |

# ១. ទិដ្ឋភាពទូទៅ៖ សេចក្តីសង្ខេបនៃបទពិសោធន៍នៃក្រុមលក់ស្រូវអង្ករនៅក្នុង FWUC បារាយណ៍

សហគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍ (FWUC) មានទីតាំងស្ថិតនៅភូមិគោកត្រាច ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប។ សហគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍បានរៀបចំ "ក្រុមលក់ស្រូវអង្ករ (PSG) ក្រោមជំនួយពី ក្រុមការងារទីផ្សារនៃមណ្ឌលសេវាកម្មធារាសាស្ត្រ (ISC) និងបណ្តាញកសិករ និងទឹក (FWN)។ គេបានអនុវត្តសកម្មភាពនេះនាខែសីហា និងខែកញ្ញា ឆ្នាំ ២០១៦ ។

គោលបំណងចម្បងនៃក្រុមលក់ស្រូវអង្ករ គឺដើម្បីលក់ស្រូវក្នុងតម្លៃខ្ពស់ជាងតម្លៃដែលកសិករច្រើនតែទទួលបាន និងដើម្បីទទួលបានតម្លៃស្មើគ្នាសម្រាប់សមាជិកនៅតំបន់ផ្សេងៗក្នុងភូមិ ប្រសិនបើអង្កររបស់ពួកគាត់មានគុណភាពដូចគ្នា ហើយមានតម្លៃប្រហាក់ប្រហែលគ្នារវាងការប្រមូលផលដំបូង និងចុងក្រោយ។

ក្រុមលក់ស្រូវអង្ករនៃសហគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍មានសមាជិកចំនួន ១៧ រូបដែលបានលក់ស្រូវរបស់ពួកគេ។ ពួកគាត់បានលក់ស្រូវចំនួន ៥៨, ៣២៦ គីឡូក្រាមតាមរយៈក្រុមលក់ស្រូវអង្ករទៅឱ្យអ្នកទិញតែម្នាក់ប៉ុណ្ណោះ គឺរោងម៉ាស៊ីនកិនស្រូវ "១៦៨៨" ដែលមានទីតាំងនៅក្នុងខេត្តកំពង់ធំ។

ដោយផ្អែកលើការវិភាគសេដ្ឋកិច្ច សមាជិកក្រុមលក់ស្រូវអង្ករបានទទួលតម្លៃស្រូវខ្ពស់ជាង កសិករក្នុងតំបន់ ដែលមិនមែនជាសមាជិកចំនួន ៩.០៤% ។ ហើយ FWUC និង បណ្តាញកសិករ និងទឹក ក៏អាចរកប្រាក់ចំណូលខ្លះៗផងដែរ ក៏ប៉ុន្តែប្រាក់ចំណូលនេះ ពុំទាន់គ្រប់គ្រាន់ ដើម្បីទូទាត់ការចំណាយរបស់គេលើការទ្រទ្រង់ប្រត្តិបត្តិការនេះនៅឡើយ។

ក្រុមលក់ស្រូវអង្ករនៃសហគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍ ដែលបានសហការជាមួយរោងម៉ាស៊ីនកិនស្រូវ ១៦៨៨ បានដំណើរការយ៉ាងរលូន ដោយសារតែមានការចូលរួមយ៉ាងល្អពីសំណាក់សមាជិកគណៈកម្មការ FWUC អាជ្ញាធរក្នុងតំបន់ និងសមាជិករបស់ខ្លួន។ ហើយក៏មានការសហការដ៏ប្រសើររវាងសមាជិក និង សមាជិកគណៈកម្មការ FWUC និងរោងម៉ាស៊ីនផងដែរ។ លើសពីនេះទៅទៀត សមាជិក PSG មានទំនុកចិត្តយ៉ាងមុតមាំលើគណៈកម្មាធិការ FWUC ដែលជាចំណុចជោគជ័យដ៏សំខាន់មួយ ជាពិសេសនៅក្នុងដំណើរការបង់ប្រាក់ ដោយសារតែការបង់ប្រាក់មិនមែនធ្វើឡើងភ្លាមៗ បន្ទាប់ពីការប្រគល់ស្រូវឱ្យអតិថិជនឡើយ។

ទោះបីជាមានបទពិសោធន៍សាកល្បងនេះក៏ដោយ ក៏សមាជិកគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍មិនទាន់មានទំនុកចិត្តក្នុងការពង្រីកប្រតិបត្តិការនេះ ដោយគ្មានជំនួយ (ពី FWN និង ISC) នៅឆ្នាំបន្ទាប់ឡើយ។ ពួកគេជឿថា គេនឹងត្រូវការជំនួយ និងការគាំទ្របន្ថែមសម្រាប់រយៈពេលមួយ ឬពីរឆ្នាំបន្ថែមទៀត។

**ប្រអប់ ១៖ ការវិភាគហានិភ័យក្នុងករណីក្រុមលក់ស្រូវអង្គរ និងរោងម៉ាស៊ីនកិនស្រូវ**

នៅពេល FWUC បានរៀបចំក្រុមលក់ស្រូវអង្គរ និងសហការជាមួយរោងម៉ាស៊ីនកិនស្រូវ ហានិភ័យនៃ FWUC ត្រូវបានវិភាគដូចខាងក្រោម៖

- FWUC អាចប្រឈមនឹងហានិភ័យពាក់ព័ន្ធនឹងការដឹកជញ្ជូនស្រូវរបស់សមាជិកទៅរោងម៉ាស៊ីនកិនស្រូវ ដោយម្ចាស់រោងម៉ាស៊ីនឱ្យតម្លៃស្រូវនៅនឹងមាត់ទ្វាររោងម៉ាស៊ីនតែម្តង។.
- FWUC អាចប្រឈមនឹងហានិភ័យពាក់ព័ន្ធនឹងការគ្រប់គ្រងគុណភាពស្រូវរបស់សមាជិក ដោយសារតែម្ចាស់រោងម៉ាស៊ីនធ្វើការគ្រប់គ្រងគុណភាពស្រូវនៅនឹងមាត់ទ្វាររោងម៉ាស៊ីនតែម្តង។
- FWUC អាចប្រឈមនឹងហានិភ័យពាក់ព័ន្ធនឹងការបង់ប្រាក់សម្រាប់ស្រូវរបស់សមាជិក ដោយសារតែម្ចាស់រោងម៉ាស៊ីនមិនបង់ប្រាក់ដល់សមាជិកក្រុមលក់ស្រូវអង្គរភ្លាមៗ បន្ទាប់ពីស្រូវត្រូវបានដាក់ចូលក្នុងរថយន្តទេ។
- ក៏ប៉ុន្តែ FWUC អាចរកប្រាក់ចំណូលបានជាច្រើនពីសកម្មភាពជាមួយ រោងម៉ាស៊ីនកិនស្រូវនេះ ដោយសារម្ចាស់រោងម៉ាស៊ីនឱ្យតម្លៃខ្ពស់ជាងតម្លៃដែលគេទៅទិញដល់កន្លែងដែលកសិករក្នុងតំបន់ច្រើនទទួលបាន។

# ២. ដើមកំណើតនៃសកម្មភាព និងការចូលរួមរបស់ភាគីពាក់ព័ន្ធ

## ២.១ ដើមកំណើតនៃសកម្មភាព

AFD បានផ្តល់មូលនិធិដល់ SCCRP ។ ក្នុងគោលបំណង គាំទ្រការអនុវត្ត យុទ្ធសាស្ត្រជាតិលើកកម្ពស់ផលិតកម្មស្រូវ និងការនាំចេញអង្ករដែលអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនាខែកក្កដា ឆ្នាំ ២០១០ ដែលមានគោលដៅបង្កើនជាអតិបរមានូវតម្លៃបន្ថែម និងចំណែកនៃតម្លៃបន្ថែមនេះដែលទៅដល់អ្នកផលិត ដែលជាផ្នែកមួយនៃគោលដៅរួមនៃការកាត់បន្ថយភាពក្រីក្រនៅតំបន់ដាច់ស្រយាល។

ISC (តាមរយៈកិច្ចសន្យារវាង FWN និង ISC) បានបង្កើតក្រុមលក់ស្រូវអង្គរ នៅក្នុងសហគមន៍កសិករ ប្រើប្រាស់ទឹកបារាយណ៍ដោយមានប្រភេទស្រូវសែនក្រអូប ពីខែសីហា ដល់ខែកញ្ញា ឆ្នាំ ២០១៦ ដោយផ្អែកលើអនុស្សារណៈនៃការយោគយល់គ្នា (No.CKH-១០៧៧-C#៣-S-១៦-០១) រវាង SNEC ដែលជាភ្នាក់ងារសម្របសម្រួលនៃ SCCRP និង FWN នៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៦ ដែលមានគោលបំណងគាំទ្រ ការចូលរួមនៃ FWUC នានា ក្នុងការធ្វើពាណិជ្ជូបនីយកម្មស្រូវ និងអភិវឌ្ឍន៍សមត្ថភាពគាំទ្ររបស់ FWN ។ ក្រុមលក់ស្រូវអង្គរនៅក្នុងសហគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍ បានរួមសហការណ៍ជាមួយនឹងរោងម៉ាស៊ីនកិនស្រូវ ១៦៨៤ ។

## ២.២. ការចូលរួមរបស់ភាគីពាក់ព័ន្ធសំខាន់ៗ

### សហគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍ (BARAY FWUC)

សហគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍ ត្រូវបានចុះបញ្ជីនៅក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) ក្នុងឆ្នាំ ២០០៣ ហើយ MOWRAM បានប្រគល់សហគមន៍នេះជូនអាជ្ញាធរអប្សរាក្នុងឆ្នាំ ២០១៤ ។ FWUC បារាយណ៍ មានទីតាំងស្ថិតនៅក្នុងភូមិគោកត្រាច ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប ។ គម្រោងធារាសាស្ត្របារាយណ៍ មានដីស្រែទំហំ ៤០០០ ហិកតា។ សហគមន៍នេះគ្របដណ្តប់ភូមិចំនួន ៦៤ នៅក្នុងឃុំចំនួន ៩ នៅស្រុកពួក ខេត្តសៀមរាប។ សម្រាប់កំឡុងពេលប្រមូលផលនាខែកញ្ញា ឆ្នាំ២០១៦ ផ្ទៃដីសរុបនៃផលិតកម្មស្រូវអង្ករមានចំនួន ៧០០ ហិកតា ជាមួយនឹងពូជស្រូវជាច្រើនមុខរបស់ពូជស្រូវសែនក្រអូប។

### មជ្ឈមណ្ឌលផ្តល់សេវាធារាសាស្ត្រ (ISC)

មជ្ឈមណ្ឌលផ្តល់សេវាធារាសាស្ត្រ (ISC) គឺជាអង្គការកម្ពុជាដែលមានជំនាញផ្នែកផ្តល់សេវាកម្ម ការកសាងសមត្ថភាព និងការគាំទ្រដល់សហគមន៍ និងគម្រោងកសិករប្រើប្រាស់ទឹកដែលបានចូលរួមក្នុងវិស័យធារាសាស្ត្រនេះ។ ជាផ្នែកមួយនៃគម្រោងនេះ មជ្ឈមណ្ឌលសេវាធារាសាស្ត្រអនុវត្តសកម្មភាពចំនួនពីរប្រភេទគឺ ១. គាំទ្រដោយផ្ទាល់ដល់សមាជិក និងលេខាធិការរបស់គណៈកម្មាធិការ FWN និង ២. គាំទ្រសេវាដល់សហគមន៍កសិករប្រើប្រាស់ទឹកដែលបានចូលរួមក្នុងម៉ូដែលក្រុមលក់ស្រូវអង្ករ (PSG) ។

### បណ្តាញកសិករ និងទឹក (FWN)

បណ្តាញកសិករ និងទឹក (FWN) គឺជាសហព័ន្ធតំណាងនៃសហគមន៍កសិករប្រើប្រាស់ទឹកនៅក្នុងប្រទេសកម្ពុជាដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃនាឆ្នាំ ២០១១ ។ សព្វថ្ងៃនេះ FWN មានសមាជិកចំនួន ២៦ នាក់ (សហគមន៍កសិករប្រើប្រាស់ទឹកចំនួន ២៦ នាក់ដែលប្រមូលផ្តុំបានគ្រួសារចំនួន ៣៤,៩៥៨ ជាមួយនឹងផ្ទៃដីស្រែសរុបចំនួន ៤១,៩៨០ នៅក្នុងខេត្តចំនួន ១១)។

### រោងម៉ាស៊ីនកិនស្រូវ ១៦៨៨ (អ្នកទិញ)

អ្នកទិញគឺជារោងម៉ាស៊ីនកិនស្រូវ (មានឈ្មោះថា "រោងម៉ាស៊ីនកិនស្រូវ ១៦៨៨") ដែលមានទីតាំងនៅភូមិប្រឡាយគោល ស្រុកស្ទួង ខេត្តកំពង់ធំ។ ម្ចាស់រោងម៉ាស៊ីននេះ មានលទ្ធភាពទិញស្រូវប្រហែល ១០០ តោនក្នុងមួយថ្ងៃ ។ ចាប់ពីក្រុមលក់ស្រូវអង្ករបស់សហគមន៍កសិករប្រើប្រាស់ទឹក រោងម៉ាស៊ីនកិនស្រូវនេះអាចស្រូបកិនស្រូវចំណុះតែពីរឡានក្នុងមួយថ្ងៃប៉ុណ្ណោះ (ឧទាហរណ៍៖ ពីចន្លោះ ៥០ ទៅ ៦០ តោនក្នុងមួយថ្ងៃ)។

## ៣. ដំណើរការនៃការអនុវត្ត

ជំហានចម្បងនៃការអនុវត្តប្រតិបត្តិការ "ក្រុមលក់ស្រូវ" សាកល្បងនៅសហគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍មានបង្ហាញដូចខាងក្រោម (ប្រតិទិនលម្អិតនៃការអនុវត្តដែលមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ១)។

ជំហានទី១៖ ការបង្កើតក្រុមលក់ស្រូវ

- ISC បានរៀបចំកិច្ចប្រជុំជាមួយសមាជិកគណៈកម្មាធិការ FWUC ដើម្បីរៀបចំកាលវិភាគសម្រាប់កិច្ចប្រជុំស្តីពីក្រុមលក់ស្រូវ នៅក្នុងឃុំកែវពណ៌ និងសំរោងយា។

- ISC និងសមាជិកគណៈកម្មាធិការ FWUC បានរៀបចំកិច្ចប្រជុំជាមួយកសិករនៅកម្រិតភូមិក្នុងឃុំកែវពណ៌ ដើម្បីស្វែងរកកសិករដែលមានចំណាប់អារម្មណ៍។
- ISC និងសមាជិកគណៈកម្មាធិការ FWUC បានបង្កើតគម្រោងផែនការបុគ្គល ហើយ ISC បានបង្កើតការបញ្ចូលទិន្នន័យ។

ជំហានទី២៖ ការស្វែងរកទីផ្សារ

- ISC បានបង្កើតតម្លៃស្ទង់មតិទាំងខាងក្នុង និងខាងក្រៅតំបន់ស្រោចស្រព ហើយស្វែងរកអ្នកទិញ និងស្វែងរកកម្មករផ្ទុកស្រូវ ព្រមទាំងស្វែងរកឡានសម្រាប់ដឹកជញ្ជូនស្រូវ។
- ISC បានរៀបចំកិច្ចប្រជុំជាមួយ FWUC (ឃុំកែវពណ៌ និងសំរោងយា ព្រមទាំងមេភូមិក្នុងឃុំសំរោងយា) ដើម្បីពិភាក្សា និងជ្រើសរើសអ្នកទិញដ៏ល្អបំផុត។
- ISC និងសមាជិកគណៈកម្មាធិការ FWUC បានបន្តបង្កើតគម្រោងផែនការបុគ្គល ហើយ ISC បានបង្កើតការបញ្ចូលទិន្នន័យ និងរៀបចំកាលវិភាគសម្រាប់ការលក់ស្រូវក្នុងថ្ងៃនីមួយៗ។

ជំហានទី៣៖ ការរៀបចំមុនពេលលក់ស្រូវ

- ISC បានរៀបចំឯកសារ និងឧបករណ៍សម្រាប់ការប្រើប្រាស់នៅក្នុងប្រតិបត្តិការលក់ ជាមួយនឹងរោងម៉ាស៊ីនកិនស្រូវ ១៦៨៨ ។

ជំហានទី៤៖ ប្រតិបត្តិការក្នុងអំឡុងពេលលក់ស្រូវ

- អំឡុងពេលប្រតិបត្តិការលក់ ISC បានបង្កើតការត្រួតពិនិត្យគុណភាពស្រូវទៅលើសមាជិក មុនពេលលើកស្រូវដាក់ឡាន។ ដោយមានការគាំទ្រពី ISC បន្ទាប់ពីលើកដាក់ស្រូវទៅលើឡានមួយហើយ សមាជិកម្នាក់ពី FWUC បានទៅកាន់រោងម៉ាស៊ីនកិនស្រូវ ១៦៨៨ តាមឡានដឹកស្រូវ ដើម្បីតាមដានការដឹកជញ្ជូន។
- នៅពេលឡានដឹកស្រូវមកដល់រោងម៉ាស៊ីនកិនស្រូវ ១៦៨៨ ISC និងសមាជិកម្នាក់ទៀតពី FWUC ធ្វើការតាមដានលើការត្រួតពិនិត្យគុណភាពស្រូវ និងដំណើរការនៃការទិញស្រូវរបស់ម្ចាស់រោងម៉ាស៊ីនកិនស្រូវ។ ជាចុងក្រោយ ម្ចាស់រោងម៉ាស៊ីនកិនស្រូវបានផ្តល់ជូនតម្លៃទិញពិតប្រាកដដល់ FWUC និងចេញមូលប្បទានបត្រជូន FWUC ។

ជំហានទី៥៖ ប្រតិបត្តិការក្រោយការលក់ស្រូវ

- ដោយមានការគាំទ្រពី ISC ពីរបីថ្ងៃក្រោយថ្ងៃលក់ស្រូវ មនុស្សបី ឬបួននាក់ក្នុងចំណោមសមាជិកគណៈកម្មាធិការ FWUC បានទៅធនាគារ ដើម្បីដកប្រាក់។ នៅពេលពួកគេមកដល់ FWUC ពួកគេបានរៀបចំលុយ និងប័ណ្ណទូទាត់ថ្លៃស្រូវ សម្រាប់សមាជិកនីមួយៗ ផ្អែកទៅតាមប័ណ្ណទម្ងន់ស្រូវនីមួយៗ។ អ្នកតំណាងក្រុមបានជូនដំណឹងទៅសមាជិក អំពីការទូទាត់ថ្លៃស្រូវរបស់ FWUC ។ ISC បានចាប់ផ្តើមរៀបចំរបាយការណ៍សកម្មភាពស្តីពីក្រុមលក់ស្រូវសម្រាប់ខែកញ្ញា ឆ្នាំ ២០១៦ ។
- FWUC ដោយមានការគាំទ្រពី ISC បានបង់ប្រាក់ទៅឲ្យសមាជិកក្រុមលក់ស្រូវ និងបានបង្ហាអំពីលទ្ធផល និងបទពិសោធន៍ដែលបានពីក្រុមលក់ស្រូវ ក្នុងអំឡុងថ្ងៃទូទាត់ប្រាក់ឲ្យទៅសមាជិកក្រុមលក់ស្រូវ។

# ៤. លទ្ធផលនៃប្រតិបត្តិការ

ក្នុងអំឡុងពេលកិច្ចប្រជុំភូមិ ស្តីពីក្រុមលក់ស្រូវជាមួយកសិករ ក្នុងគោលបំណងស្វែងរកកសិករដែលមានចំណាប់អារម្មណ៍ ផលប្រយោជន៍នៃក្រុមលក់ស្រូវ គឺត្រូវបានបង្ហាញ និងពន្យល់យ៉ាងក្បោះក្បាយដូចខាងក្រោម៖

- សមាជិកក្រុមលក់ស្រូវ អាចលក់ស្រូវជាមួយនឹងតម្លៃខ្ពស់ជាងតម្លៃទីផ្សារក្នុងតំបន់
- សមាជិកក្រុមលក់ស្រូវ អាចទទួលបានតម្លៃដដែល ទោះបីជាទីតាំងរបស់ពួកគេនៅក្នុងភូមិខ្លួនក៏ដោយ
- សមាជិកក្រុមលក់ស្រូវ អាចប្រមូលផលជាមុនសិន ហើយសម្រាប់អ្នកដែលប្រមូលផលក្រោយ អាចទទួលបានតម្លៃដដែល
- សមាជិកក្រុមលក់ស្រូវ បង្កើនទំនុកចិត្ត និងមានការយកចិត្តទុកដាក់យ៉ាងល្អប្រសើរពីអ្នកទិញ
- សមាជិកក្រុមលក់ស្រូវ អាចទទួលបានព័ត៌មានទីផ្សារ និងយោបល់បច្ចេកទេសថ្មីៗសម្រាប់ផលិតកម្មស្រូវ។

ក្រោយពីបង្កើតគម្រោងផែនការបុគ្គលសម្រាប់ក្រុមលក់ស្រូវជាមួយនឹងកសិករដែលមានចំណាប់អារម្មណ៍រួច មានកសិករចំនួន ១៧ នាក់ (ឧទាហរណ៍៖ កសិករចំនួន ៩ នាក់ នៅក្នុងឃុំកែវពណ៌ និងកសិករចំនួន ៨ នាក់នៅក្នុងឃុំសំរោងយា) ដែលចង់លក់ស្រូវរបស់ពួកគាត់តាមរយៈក្រុមលក់ស្រូវ ។ ពួកគាត់ចាប់ផ្តើមប្រមូលផល ពូជស្រូវ ស្រូវសែនក្រអូប ក្នុងចន្លោះថ្ងៃទី ១៧ ទៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០១៦ ។ មានតែផ្នែកនៃសមាជិក FWUC បារាយណ៍ប៉ុណ្ណោះ ដែលជាផ្នែកនៃក្រុមលក់ស្រូវ សម្រាប់មូលហេតុមួយចំនួនដូចខាងក្រោម៖

- សមាជិក FWUC មួយចំនួនមានប្រភេទស្រូវអង្ករច្រើនជាងប្រភេទអង្ករសែនក្រអូប
- សមាជិក FWUC មួយចំនួនមានដីស្រែសម្រាប់ចិញ្ចឹមខ្លួនឯងតែប៉ុណ្ណោះ
- សមាជិក FWUC មួយចំនួនធ្វើចំណាកស្រុកទៅតំបន់ផ្សេង
- សមាជិក FWUC មួយចំនួនមិនអាចធ្វើការផលិតស្រូវនៅក្នុងរយៈពេលនេះទេ ពីព្រោះមិនមានទឹកគ្រប់គ្រាន់
- សមាជិក FWUC មួយចំនួនមិនទុកចិត្តក្រុមលក់ស្រូវ ឬសមត្ថភាពក្រុមលក់ស្រូវ ក្នុងការអនុវត្តផែនការលក់ជាក់ស្តែង។

ក្រោយវាយតម្លៃអ្នកទិញដែលមានសក្តានុពលផ្សេងៗមក ក្រុមលក់ស្រូវនៅក្នុង FWUC បារាយណ៍ បានសម្រេចចិត្តសហការជាមួយ "រោងម៉ាស៊ីនកិនស្រូវ ១៦៨៨" ។ ម្ចាស់រោងម៉ាស៊ីនកិនស្រូវកំពុងដាក់តម្លៃស្រូវដោយផ្អែកទៅលើការត្រួតពិនិត្យគុណភាពស្រូវ។ គាត់មានស្តង់ដារ និងឧបករណ៍សម្រាប់ត្រួតពិនិត្យគុណភាពស្រូវនៅច្រកទ្វាររោងម៉ាស៊ីនកិនស្រូវ។ គាត់បានប្រើប្រាស់ការសិក្សាលើគំរូ (ដែកឆាំ) ដើម្បីទាញយកគំរូស្រូវ។ បន្ទាប់មក គាត់ពិនិត្យមើលសំណើមភាពសុទ្ធ និងបញ្ហាបរទេស ។ យោងទៅតាមការវាយតម្លៃនេះ គាត់បានដាក់តម្លៃស្រូវដែលនាំយកដោយសហគមន៍កសិករប្រើប្រាស់ទឹក និងបានពិនិត្យ។

កំឡុងពេលលក់ស្រូវគឺដូចទៅនឹងកំឡុងពេលប្រមូលផលស្រូវ ពីព្រោះសមាជិកក្រុមលក់ស្រូវបានលក់ស្រូវរបស់ខ្លួនក្នុងសភាពសើម (ស្រូវសើម)។ តម្លៃដែលម្ចាស់រោងម៉ាស៊ីនកិនស្រូវផ្តល់ជូន FWUC នៅច្រកទ្វាររោងម៉ាស៊ីនគឺមានតម្លៃខ្ពស់ជាងតម្លៃនៅច្រកទ្វារកសិដ្ឋានដែលកសិករអាចទទួលបាននៅក្នុងស្រុកពួក។ ប្រាក់ចំណេញរវាងតម្លៃនៅច្រកទ្វាររោងម៉ាស៊ីនដែលផ្តល់ជូន FWUC និងតម្លៃនៅច្រកទ្វារកសិដ្ឋានដែលកសិករអាចទទួលបាននៅក្នុងស្រុកពួក (ក្រៅពីក្រុមលក់ស្រូវ) គឺ ១៥០ រៀលក្នុងមួយគីឡូក្រាម (ឧទាហរណ៍៖ សម្រាប់ឡានដឹកទីមួយនៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១៦ ម្ចាស់រោងម៉ាស៊ីនដាក់តម្លៃ ៩២០ រៀលក្នុងមួយគីឡូក្រាម។ សម្រាប់ឡានដឹកទីពីរ នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ

២០១៦ គាត់ដាក់តម្លៃ ៨៩០ រៀលក្នុងមួយគីឡូក្រាម ។ រីឯនៅច្រកទ្វារកសិដ្ឋាន តម្លៃគឺ ៧៣០ រៀលក្នុងមួយគីឡូក្រាមនៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១៦ និង ៧០០ រៀលក្នុងមួយគីឡូក្រាមនៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០១៦) ។

បន្ទាប់មក FWUC បានទូទាត់តម្លៃស្មើគឺ ៧៨០ រៀលក្នុងមួយគីឡូក្រាម សម្រាប់ស្រូវ ៥៨,៣ តោន ដែលប្រគល់ជូនដោយសមាជិកក្រុមលក់ស្រូវ។ ភាពខុសគ្នារវាងតម្លៃសម្រាប់សមាជិកក្រុមលក់ស្រូវ និងតម្លៃដែលទទួលបានដោយកសិករក្រៅពីក្រុមលក់ស្រូវ (សម្រាប់ស្រូវដែលស្រដៀងគ្នា) គឺមានតម្លៃនៅចន្លោះពី +៥០ រៀល ទៅ +៨០ រៀលក្នុងមួយគីឡូក្រាម។ ក្នុងកំឡុងពេលលក់ស្រូវ តម្លៃស្រូវនៅច្រកទ្វារកសិដ្ឋានមានភាពខុសគ្នា ក្នុងចន្លោះពី ៧០០ រៀលក្នុងមួយគីឡូក្រាម ទៅ ៧៣០ រៀលក្នុងមួយគីឡូក្រាម។

ជាលទ្ធផល ស្រូវសើមចំនួន ៥៨,៣២៦ គីឡូក្រាម (ពោលគឺស្រូវចំនួន ៣១,៥៥៦ គីឡូក្រាមពីសមាជិកចំនួន ៩ រូបនៅក្នុងឃុំកែវពណ៌ និងចំនួន ២៦,៧៧០ គីឡូក្រាមពីសមាជិកចំនួន ៨ រូបនៅក្នុងឃុំសំរោងយា) ត្រូវបានលក់តាមរយៈ ក្រុមលក់ស្រូវ (PSG) នៅក្នុង FWUC បារាយណ៍។ លើសពីនេះទៅទៀត FWUC បារាយណ៍បង់ប្រាក់ ១០ រៀលក្នុងមួយគីឡូក្រាម (ពោលគឺមានទឹកប្រាក់សរុបចំនួន ១៤៥,៨៣ ដុល្លារលើបរិមាណស្រូវសរុបចំនួន ៥៨,៣២៦ គីឡូក្រាម) ឱ្យ FWN សម្រាប់ការគាំទ្រដែលផ្តល់ដោយ FWN និង ISC ។

ក្រុមលក់ស្រូវ (PSG) នៅក្នុង FWUC បារាយណ៍ដែលបានសហការជាមួយរោងម៉ាស៊ីនកិនស្រូវ ១៦៨៨ គឺមានដំណើរការយ៉ាងរលូនដោយសារមានការចូលរួមយ៉ាងល្អពីសំណាក់សមាជិកគណៈកម្មាធិការ FWUC និងសមាជិករបស់ខ្លួន។ វាមានការសហការយ៉ាងល្អរវាងសមាជិក និងសមាជិកគណៈកម្មាធិការ FWUC និងម្ចាស់រោងម៉ាស៊ីនកិនស្រូវ។ មិនត្រឹមតែប៉ុណ្ណោះ សមាជិក ក្រុមលក់ស្រូវ (PSG) មានជំនឿទុកចិត្តយ៉ាងមុតមាំលើសមាជិកគណៈកម្មាធិការ FWUC ជាពិសេសពាក់ព័ន្ធនឹងដំណើរការការបង់ប្រាក់របស់ FWUC (ឧទាហរណ៍ ការមិនបង់ប្រាក់ឱ្យភ្លាមៗ)។

ផ្ទុយទៅវិញ គេបានកត់សម្គាល់ឃើញថាមានបញ្ហាតិចតួចកើតមានឡើងផងដែរ៖ ឧទាហរណ៍ សមាជិកគណៈកម្មាធិការមិនបាន គោរពលើការផ្តល់អទិភាព (នៅពេលដែលធ្វើការប្រមូល និងការថ្លឹងស្រូវ) ដល់សមាជិក PSG នោះទេ (សមាជិកដែលពីមុនបានប្តេជ្ញាចិត្តលក់តាមរយៈ PSG នៅក្នុងដំណាក់កាលរៀបចំផែនការ) ជាជាងផ្តល់ឱ្យសមាជិកថ្មីដែលព្យាយាមលក់តាមរយៈ PSG ខណៈពេលដែលពួកគេនោះមិនមានការចុះឈ្មោះក្នុងបញ្ជីឡើយ។

# ៥. ការវិភាគសេដ្ឋកិច្ច

ការវិភាគសេដ្ឋកិច្ចលើសកម្មភាពរបស់ PSG នៅក្នុង FWUC បារាយណ៍ គឺផ្តោតសំខាន់លើ FWUC សមាជិក PSG កសិករធម្មតា និង ISC/FWN។

## ៥.១. ការវិភាគលទ្ធផលសេដ្ឋកិច្ចនៅកម្រិត FWUC

FWUC បារាយណ៍បានទទួលប្រាក់ចំណូលសរុបចំនួន ១៣,២៦៩.២៥ ដុល្លារ ពីសកម្មភាព PSG (ការលក់ស្រូវ) នៅក្នុងខែកញ្ញា ២០១៦ ។ ផ្ទុយទៅវិញ ថ្លៃចំណាយលើសកម្មភាពទិញស្រូវនេះ (ការទិញស្រូវ ថ្លៃចំណាយពលកម្ម ការដឹកជញ្ជូន ការបង់ប្រាក់ទៅឱ្យ FWN និងថ្លៃចំណាយផ្សេងៗទៀត) មានចំនួនសរុបទៅដល់ ១២,២០៦.០៨ ដុល្លារ។

ដូច្នេះ ប្រាក់ចំណេញរបស់ FWUC បារាយណ៍ដែលបានពីសកម្មភាព PSG មានចំនួន ១,០៦៣.៤៣ ដុល្លារ ឬក៏ ៨.៧១% នៃថ្លៃចំណាយសរុបរបស់ខ្លួន។ ថ្លៃចំណាយប្រតិបត្តិការរបស់ FWUC បារាយណ៍ទៅលើ PSG នាខែកញ្ញា

ឆ្នាំ ២០១៦ មានចំនួនទឹកប្រាក់ ៦៨៦.៧៣ ដុល្លារ (ដែលមិនរួមបញ្ចូលការបង់ប្រាក់ទៅឱ្យសមាជិកម្ចាស់ស្រូវ និងការបង់ប្រាក់ទៅឱ្យ FWN)។ ព័ត៌មានលម្អិតបានផ្តល់ជូននៅក្នុងតារាងទី ១ ខាងក្រោម។

**តារាងទី១៖ ប្រាក់ចំណូល និងការចំណាយរបស់ប្រតិបត្តិការក្រុមលក់ស្រូវនៅកម្រិត FWUC នៅក្នុងស្រុកបារាយណ៍**

| | | | |
|---|---|---|---|
| **I.** | **ប្រាក់ចំណូលរបស់ FWUC ពី PSG គិតជា ដុល្លារ** | | **១៣,២៦៩.៥០ ដុល្លារ** |
| ១.១. | ការលក់ស្រូវ - សែនក្រអូបលើកទី ១ (២៩,៧៥០ គីឡូ × ៩២០ រៀល) | ៦,៨៤២.២៧ ដុល្លារ | |
| ១.២. | បរិមាណស្រូវលើសតម្រូវការលើកទី ១ (១០១ គីឡូ × ៩២០ រៀល) | ២៣.២៣ ដុល្លារ | |
| ១.៣. | ការលក់ស្រូវ - សែនក្រអូបលើកទី ២ (២៨,៥៧៦គីឡូ × ៨៩០ រៀល) | ៦,៣៥៧.៩៤ ដុល្លារ | |
| ១.៤. | បរិមាណស្រូវលើសតម្រូវការលើកទី ២ (២០៧គីឡូ × ៨៩០ រៀល) | ៤៦.០៦ ដុល្លារ | |
| **II.** | **ប្រាក់ចំណាយរបស់ FWUC ពី PSG គិតជា ដុល្លារ** | | **១២,២០៦.០៨ ដុល្លារ** |
| ២.១. | ថ្លៃចំណាយពលកម្ម | ២២៧.៥០ ដុល្លារ | |
| *២.១.១.* | *ថ្លៃពលកម្មលើការរៀបចំគម្រោង* | ៣៥.០០ ដុល្លារ | |
| *២.១.២.* | *ថ្លៃពលកម្មលើការផ្ទុក* | ១៤២.៥០ ដុល្លារ | |
| *២.១.៣.* | *ថ្លៃពលកម្មលើការថ្លឹង* | ២៥.០០ដុល្លារ | |
| *២.១.៤.* | *ថ្លៃពលកម្មលើការតាមដានរថយន្ត* | ២៥.០០ដុល្លារ | |
| ២.២. | ថ្លៃមធ្យោបាយដឹកជញ្ជូន | ៤៣៥.០០ ដុល្លារ | |
| ២.៣. | ការទិញស្រូវពីសមាជិក | ១១,៣៧៣.៥៣ ដុល្លារ | |
| ២.៤. | ការចំណាយលើ FWN | ១៤៥.៨៣ ដុល្លារ | |
| ២.៥. | ចំណាយផ្សេងៗ | ២៤.២៣ ដុល្លារ | |
| *២.៥.១.* | *ទឹកបរិសុទ្ធ និងអាហារសម្រន់* | *៧.២៥ ដុល្លារ* | |
| *២.៥.២.* | *អាហារ* | *១២.៥០ ដុល្លារ* | |
| *២.៥.៣.* | *សេវាធនាគារ* | *៤.៤៨ ដុល្លារ* | |
| **III.** | **ប្រាក់ចំណេញរបស់ FWUC ពី PSG គិតជាដុល្លារ** | | **១,០៦៣.៤៣ ដុល្លារ** |

## ៥.២. ការវិភាគលើលទ្ធផលសេដ្ឋកិច្ចសម្រាប់សមាជិក PSG

សមាជិករបស់ PSG នៅក្នុង FWUC បារាយណ៍បានលក់ស្រូវសើមសែនក្រអូបរបស់ពួកគេនៅក្នុងបរិមាណសរុបចំនួន ៥៨,៣២៦ គីឡូក្រាម។ ពួកគេទទួលបានប្រាក់ចំណូលសរុបចំនួន ១១,៣៧៣.៥៣ ដុល្លារតាមរយៈ PSG ។

ប្រសិនបើពួកគេលក់ស្រូវរបស់ពួកគេនៅក្នុងបរិមាណដូចគ្នារៀងៗខ្លួនទៅឱ្យអ្នកប្រមូលទិញនៅក្នុងតំបន់ គេប៉ាន់ស្មានថាពួកគេនឹងទទួលបានប្រាក់ត្រឹមតែចំនួន ១០,៤៣០.១៨ ដុល្លារប៉ុណ្ណោះ។ ប្រាក់ចំណូលបន្ថែមសម្រាប់កសិករបានឈានទៅដល់ +៩៤៣.៣៥ ដុល្លារ (ប្រមាណ +៦៥ ដុល្លារ/គីឡូ) ពោលគឺ ការកើនឡើងមួយក្នុងចំនួន +៩.០៤% ធៀបនឹងតម្លៃនៅមាត់ទ្វារកសិដ្ឋានក្នុងមូលដ្ឋាន។

ព័ត៌មានលម្អិតផ្តល់ជូននៅក្នុងតារាងទី ២ ខាងក្រោម។

តារាងនេះវិភាគតែលើភាពខុសគ្នារវាងតម្លៃដែលទទួលបានពីការលក់របស់កសិករតាមក្រុមលក់ស្រូវរបស់ FWUC ធៀបនឹងតម្លៃដែលពួកគេនឹងទទួលបានពីអ្នកប្រមូលទិញនៅក្នុងតំបន់ (នៅមាត់ទ្វារកសិដ្ឋាន)។ ការវិភាគមួយលើថ្លៃច្រូតស្រូវ ប្រាក់ចំណូល និងប្រាក់ចំណេញ (ផ្អែកតាមតម្លៃអ្នកប្រមូលក្នុងតំបន់) គឺបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ២ ។

**តារាង ២៖ តម្លៃដែលទទួលបានពីកសិករនៅក្នុង PSG និងការប្រៀបធៀបលើតម្លៃដែលពួកគេអាចទទួលបានក្រៅពី PSG**

| | | |
|---|---|---|
| I. | **ប្រាក់ទទួលបានពីសមាជិក PSG សម្រាប់ស្រូវរបស់ពួកគេ (*ស្រូវសែនក្រអូប* = ៥៨,៣២៦ គីឡូ)** | **១១,៣៧៣.៥៣ ដុល្លារ** |
| ១.១. | ប្រតិបត្តិការលក់លើកទី ១ (២៩,៧៥០ គីឡូ × ៧៨០ រៀល) | ៥,៨០១.១៥ ដុល្លារ |
| ១.២. | ប្រតិបត្តិការលក់លើកទី២ (២៨,៥៧៦ គីឡូ × ៧៨០ រៀល) | ៥,៥៧២.៣៨ ដុល្លារ |
| II. | **ប្រាក់ដែលកសិករអាចនឹងទទួលបានលើការលក់ស្រូវដូចគ្នា (*ស្រូវសែនក្រអូប* = ៥៨,៣២៦ គីឡូ ក្រៅពី PSG (យោងតាមតម្លៃរាយដែលផ្តល់ដោយអ្នកប្រមូលទិញក្នុងតំបន់នៅថ្ងៃដូចគ្នា)** | **១០,៤៣០.១៨ ដុល្លារ** |
| ២.១. | ប្រតិបត្តិការលក់លើកទី ១ (២៩,៧៥០ គីឡូ × ៧៣០ រៀល) | ៥,៤២៩.៣៨ ដុល្លារ |
| ២.២. | ប្រតិបត្តិការលក់លើកទី ២ (២៨,៥៧៦ គីឡូ × ៧០០ រៀល) | ៥,០០០.៨០ ដុល្លារ |
| III. | **ប្រាក់ចំណេញរបស់សមាជិកលើការលក់ស្រូវ (*សែនក្រអូប* = ៥៨,៣២៦ គីឡូ) នៅក្នុង PSG គិតជាដុល្លារ** | **៩៤៣.៣៥ ដុល្លារ** |

### ៥.៣. ការវិភាគសេដ្ឋកិច្ចសម្រាប់ ISC/FWN

ISC បានប្រើប្រាស់បុគ្គលិក ៤ នាក់ (ពោលគឺ អ្នកជំនាញផ្នែកទីផ្សារម្នាក់ មន្ត្រីផ្នែកទីផ្សារម្នាក់ និងអ្នកសម្របសម្រួលលើដីស្រែ ២ នាក់) ដើម្បីគាំទ្រ FWUC បារាយណ៍លើសកម្មភាព PSG ពីខែសីហា ដល់ ខែកញ្ញា ឆ្នាំ ២០១៦ ។ ថ្ងៃធ្វើការសរុបរបស់បុគ្គលិកទាំងអស់ដែលចំណាយសម្រាប់សកម្មភាពនេះគឺចំនួន ៣៦ ថ្ងៃ។ ថ្លៃចំណាយប្រតិបត្តិការរបស់ ISC សម្រាប់ការគាំទ្រ PSG នៅក្នុង FWUC បារាយណ៍មានចំនួន ១,៥៥៣.៣៩ ដុល្លារ សម្រាប់ចំនួនថ្ងៃធ្វើការសរុបរបស់បុគ្គលិកទាំងអស់។

## ៦. លទ្ធភាព៖ ភាពខ្លាំង ភាពខ្សោយ និងការមើលទុកមុននាពេលអនាគតនៃការផ្តួចផ្តើមនេះ

### ៦.១. ការវិភាគរបស់ចំណុចរួចដើមក្នុង FWUC បារាយណ៍

សម្រាប់ការវិភាគលើចំនុចរួចដើមរបស់ PSG ក្នុង FWUC បារាយណ៍ យើងត្រូវការដឹងអំពីថ្លៃចំណាយថេរសរុប ថ្លៃចំណាយប្រែប្រួលក្នុង ១ តោន ប្រាក់ចំណូលក្នុង ១ តោន និងបរិមាណស្រូវបានលក់សរុប។

ថ្លៃចំណាយប្រតិបត្តិការរបស់ ISC សម្រាប់សកម្មភាព PSG គឺមានទឹកប្រាក់សរុបចំនួន ១,៥៥៣.៣៩ ដុល្លារ រួមបញ្ចូលថ្លៃចំណាយថេរសរុប (៥៤៧.៦០ ដុល្លារ ដែលវាបានមកពីថ្លៃចំណាយទាំងអស់លើការគាំទ្រសកម្មភាព PSG នៅក្នុងជំហានទី ១ ជំហានទី ២ ជំហានទី ៣ និងជំហានទី ៥) និងថ្លៃចំណាយប្រែប្រួល (១,០០៥.៧៩ ដុល្លារដែលវាបានមកពីថ្លៃទាំងអស់លើការគាំទ្រសកម្មភាព PSG នៅក្នុងជំហានទី ៤ "ប្រតិបត្តិការកំឡុងពេលលក់ស្រូវ"។ បន្ទាប់

មក វាត្រូវបានចែកតាមបរិមាណស្រូវដែលបានលក់ សម្រាប់ការស្វែងរកថ្លៃចំណាយប្រែប្រួលក្នុងមួយតោន) និងថ្លៃចំណាយប្រែប្រួលក្នុងមួយតោន (១៧.២៤ ដុល្លារក្នុងមួយតោន)។ លើសពីនេះទៅទៀត ថ្លៃចំណាយថេរសរុបរបស់ FWUC មានទឹកប្រាក់ ៣៥.០០ ដុល្លារ និងថ្លៃចំណាយប្រែប្រួលរបស់ FWUC មានទឹកប្រាក់ ១៣.៦៧ ដុល្លារក្នុងមួយតោន)។

- ថ្លៃចំណាយថេរសរុប = ៥៨២.៦០ ដុល្លារ
- ថ្លៃចំណាយប្រែប្រួលក្នុងមួយតោន = ៣០.៩១ ដុល្លារ
- ប្រាក់ចំណូល FWUC ក្នុងមួយតោន = ៣២.៥១ ដុល្លារ
- បរិមាណស្រូវដែលបានលក់គិតជាតោន = ៥៨.៣២៦ តោន

**តារាង ៣៖ ការវិភាគយ៉ាងលម្អិតអំពីចំណុចរួចដើមសម្រាប់ PSG នៅក្នុង FWUC បារាយណ៍**

| បរិមាណលក់ចេញ (តោន) | ប្រាក់ចំណូល FWUC | ថ្លៃចំណាយប្រែប្រួល | ថ្លៃចំណាយថេរ | ថ្លៃចំណាយសរុប | ប្រាក់ចំណេញប្រតិបត្តិការ |
|---|---|---|---|---|---|
| 0 តោន | 0 $ | 0 $ | ៥៨២.៦០ $ | ៥៨២.៦ $ | -៥៨៣ $ |
| ៥៨.៣២៦ តោន | ១,៨៩៦ $ | ១,៨០៣ $ | ៥៨២.៦០ $ | ២៣៨៥ $ | -៤៨៩ $ |
| ១០០ តោន | ៣,២៥១ $ | ៣,០៩១ $ | ៥៨២.៦០ $ | ៣៦៧៤ $ | -៤២៣ $ |
| ២០០ តោន | ៦,៥០២ $ | ៦,១៨២ $ | ៥៨២.៦០ $ | ៦៧៦៥ $ | -២៦៣ $ |
| ៣០០ តោន | ៩,៧៥៣ $ | ៩,២៧៣ $ | ៥៨២.៦០ $ | ៩៨៥៦ $ | -១០៣ $ |
| ៣៦៤.១២៣ តោន | ១១,៨៣៨ $ | ១១,២៥៥ $ | ៥៨២.៦០ $ | ១១៨៣៨ $ | 0.00 $ |
| ៤០០ តោន | ១៣,០០៤ $ | ១២,៣៦៤ $ | ៥៨២.៦០ $ | ១២៩៤៧ $ | ៥៧ $ |
| ៤៥០ តោន | ១៤,៦៣០ $ | ១៣,៩១០ $ | ៥៨២.៦០ $ | ១៤៤៩២ $ | ១៣៧ $ |
| ៥០០ តោន | ១៦,២៥៥ $ | ១៥,៤៥៥ $ | ៥៨២.៦០ $ | ១៦០៣៨ $ | ២១៧ $ |
| ៥៥០ តោន | ១៧,៨៨១ $ | ១៧,០០១ $ | ៥៨២.៦០ $ | ១៧៥៨៣ $ | ២៩៧ $ |

→ តួរលេខពិតប្រាកដ សម្រាប់ឆ្នាំ ២០១៦ (ជួរ ៥៨.៣២៦ តោន)

→ ចំណុចរួចដើម (ជួរ ៣៦៤.១២៣ តោន)

យោងតាមតារាងលេខ ៣ ខាងលើ យើងសង្កេតឃើញថា ចំណុចរួចដើមសម្រាប់ PSG នៅក្នុង FWUC បារាយណ៍គឺមានចំនួន ៣៦៤ តោន។ ប្រសិនបើបរិមាណលក់ចេញមានកម្រិតស្ថិតនៅក្រោមបរិមាណខាងលើ នោះ FWUC បារាយណ៍នឹងមានការខាតបង់ថវិកា។ ប្រសិនបើបរិមាណលក់ចេញមានកម្រិតច្រើនជាងបរិមាណខាងលើ នោះ FWUC អាចទទួលបានផលចំណេញ។

រូបភាព ១៖ ការតំណាងក្រាហ្វអំពីចំណុចរួចដើម




## ៦.២. ភាពខ្លាំង និងភាពខ្សោយ

ក្រោយពីបញ្ចប់សកម្មភាព PSG នៅក្នុង FWUC បារាយណ៍រួចមក FWN និង ISC បានធ្វើការត្រួតពិនិត្យ និងបានគូសបញ្ជាក់អំពីចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈមសំខាន់ៗដូចដែលមានរៀបរាប់នៅខាងក្រោម៖

### ចំណុចខ្លាំង

- មានការចូលរួមយ៉ាងសកម្មពីសំណាក់សមាជិកគណៈកម្មការរបស់ FWUC អាជ្ញាធរមូលដ្ឋាន និងសមាជិក
- សមាជិកមានទំនុកចិត្តខ្លាំងលើ FWUC ទាក់ទងនឹងការបង់ប្រាក់យឺតសម្រាប់ PSG
- មានកិច្ចសហការល្អរវាង សមាជិកគណៈកម្មការ FWUC ជាមួយនឹងសមាជិក និងអ្នកទិញ។

### ចំណុចខ្សោយ

- សមាជិកគណៈកម្មការ FWUC មិនគោរពតាមគោលការណ៍របស់ PSG ។
- សមាជិកមិនគោរពតាមគោលការណ៍របស់ PSG ។

សម្រាប់សមាជិកដែលមិនគោរពតាមគោលការណ៍របស់ PSG ផលប៉ះពាល់នេះអាចដាក់កម្រិតបានដូចតទៅ៖

- កែលម្អលក្ខខណ្ឌ ដើម្បីក្លាយជាសមាជិករបស់ PSG និងធ្វើការពន្យល់ឲ្យបានច្បាស់អំពីផលប្រយោជន៍របស់ PSG និងកត្តាមួយចំនួន (ដូចជា ភាពស្មោះត្រង់ សាមគ្គីភាព ស្ថានភាពរឹងមាំ) ដែលអាចធ្វើឲ្យ PSG ទទួលបានជោគជ័យ។

- ចុះជួបជាមួយសមាជិកឲ្យបានទៀងទាត់ ដើម្បីប្រាប់ពួកគេអំពីការធ្វើបច្ចុប្បន្នភាពលើគម្រោង

- ធ្វើការដកចេញចំពោះកសិករណាដែលមិនគោរពតាមអនុសាសន៍របស់ PSG ។ ហើយព្យាយាមបង្ហាញអំពីលទ្ធភាពដែលអាចអនុវត្តបានដោយជោគជ័យជាមួយសមាជិកដែលប្ដេជ្ញាគោរពតាមបទប្បញ្ញត្តិរួមគ្នាដែលបានបង្កើត។

### បញ្ហាប្រឈម

- គ្រាប់ពូជដែលប្រើប្រាស់ដោយសមាជិក PSG និងកសិករនៅក្នុងតំបន់ស្រោចស្រពមិនមានគុណភាពល្អ។
- មានភ្លៀងធ្លាក់ក្នុងអំឡុងពេលប្រមូលផល។

# ៧. លទ្ធភាពពង្រីក និងលក្ខខណ្ឌសម្រាប់ការពង្រីកដោយគ្មានការគាំទ្រពីគម្រោង SCCRP

## ៧.១. សមត្ថភាព និងដែនកំណត់របស់ FWUCS បារាយន៍ក្នុងការពង្រីកការអនុវត្តរបស់ PSG

ISC ធ្លាប់មានឧបករណ៍ និងបទពិសោធន៍លើ PSG រួចហើយ។ ទោះបីជា FWUC បារាយណ៍ ធ្លាប់មានបទពិសោធន៍លក់ស្រូវជាសមូហភាពជាលើកដំបូងក៏ដោយ គេវាយតម្លៃថា FWUC នៅពុំទាន់មានលទ្ធភាពពេញលេញ ដើម្បីដំណើរការសកម្មភាពលក់ស្រូវជាសមូហភាពនៅក្នុងរដូវកាលផលិតកម្មស្រូវបន្ទាប់ដោយឯកឯងបានឡើយ។ សេចក្តីលម្អិតអំពីអ្វីដែល FWUC អាចអនុវត្តបាននៅពេលនេះ ហើយអ្វីដែលនៅតែបន្តទាមទារការគាំទ្រពីខាងក្រៅត្រូវបានរៀបរាប់ដូចខាងក្រោម៖

អ្វីដែល FWUC បារាយណ៍ អាចធ្វើបានដោយឯកឯងមានដូចជា៖

- រៀបចំការជួបជុំកម្រិតថ្នាក់ភូមិ ដើម្បីស្វែងរកកសិករដែលមានចំណាប់អារម្មណ៍
- ធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នកទិញ
- ស្វែងរកកម្លាំងពលកម្មសម្រាប់លើកជញ្ជូនស្រូវដាក់លើរថយន្តដឹកទំនិញ
- ស្វែងរករថយន្តដឹកទំនិញសម្រាប់ដឹកជញ្ជូនស្រូវទៅកាន់រោងម៉ាស៊ីនស្រូវ។

អ្វីដែល FWUC បារាយណ៍ មិនអាចធ្វើបានដោយឯកឯងមានដូចជា៖

- ធ្វើការបញ្ចូលទិន្នន័យសម្រាប់ផែនការបុគ្គលដោយប្រើប្រាស់គំរូដែលមាននៅក្នុងឯកសារ Excel
- ធ្វើបច្ចុប្បន្នភាពអំពីផែនការជាមួយសមាជិក
- រៀបចំកាលវិភាគ និងរថយន្តដឹកទំនិញសម្រាប់ការលក់ស្រូវនៅក្នុងថ្ងៃនីមួយៗ។

ដំណោះស្រាយដែលបានស្នើឡើងសម្រាប់អ្វីដែល FWUC បារាយណ៍ មិនអាចធ្វើតែឯកឯងបានមានដូចជា៖

- FWUC អាចមានលទ្ធភាពទទួលសេវាមួយចំនួនពីខាងក្រៅ (ការចំណាយចំពោះការអនុវត្តភារកិច្ចមួយចំនួនដោយអ្នកផ្តល់សេវា) ។
- FWUC អាចជួលបុគ្គលិក ដើម្បីដំណើរការសកម្មភាព។

លទ្ធភាពនៃជម្រើសទាំងពីរនេះនឹងនៅតែត្រូវបានគេវាយតម្លៃយ៉ាងលម្អិត។

## ៧.២. ការសាកល្បងនៃការពង្រីកសកម្មភាពនៅឆ្នាំ ២០១៧ បានគូសបញ្ជាក់អំពីភាពផុយស្រួយដែលនៅសេសសល់ពីម៉ូដែល

ទោះជាលទ្ធផលនៃការអនុវត្តរបស់ក្រុមលក់ស្រូវជាសមូហភាពរបស់ FWUC បារាយណ៍ មានភាពវិជ្ជមានពាក់ព័ន្ធនឹងការបង្កើនតម្លៃបន្ថែមដែលកសិករទទួលបានសម្រាប់ស្រូវរបស់ពួកគេក៏ដោយ ការពង្រីកសកម្មភាពនៅក្នុងឆ្នាំ ២០១៧ បានទទួលការបរាជ័យ ហើយបង្ហាញថាម៉ូដែលស្ថិតនៅស្ថានភាពផុយស្រួយ។

នៅក្នុងឆ្នាំ ២០១៧ FWUC មិនបានធ្វើការគ្រប់គ្រង ដើម្បីទទួលបានតម្លៃល្អប្រសើរជាងមុន ខណៈពេលដែលមានការលក់ស្រូវដោយផ្ទាល់ទៅកាន់រោងម៉ាស៊ីនកិនស្រូវ។ មូលហេតុមួយក្នុងចំណោមហេតុផលផ្សេងៗដែលគេបានកំណត់នោះ គឺគុណភាពអន់របស់ស្រូវដែលប្រមូលផលបានជាមួយនឹងភាពសុទ្ធនៃពូជមានកម្រិតទាប។

## ឧបសម្ព័ន្ធ ១៖ ប្រតិទិនលម្អិតអំពីការអនុវត្តសកម្មភាព

| កាលបរិច្ឆេទ | សកម្មភាព |
|---|---|
| ២៩-៣១/០៨/១៧ | រៀបចំវិធីសាស្ត្រសម្រាប់ស្វែងរកកសិករដែលមានចំណាប់អារម្មណ៍ និងរៀបចំឯកសារ ព្រមទាំងឧបករណ៍សម្រាប់ប្រជុំជាមួយសមាជិកគណៈកម្មាធិការ FWUC និងអាជ្ញាធរមូលដ្ឋាន |
| ០១/០៩/១៧ | កិច្ចប្រជុំជាមួយសមាជិកគណៈកម្មាធិការ FWUC និងអាជ្ញាធរមូលដ្ឋាន |
| ០៧/០៩/១៧ | រៀបចំឯកសារ និងឧបករណ៍សម្រាប់ការបង្កើតផែនការ និងក្រុមលក់ស្រូវ |
| ០៨-១០/០៩/១៧ | ផ្តល់ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគុណភាពស្រូវដល់សមាជិកគណៈកម្មាធិការ FWUC និងកិច្ចប្រជុំជាមួយអាជ្ញាធរមូលដ្ឋាននៅកម្រិតភូមិ ដើម្បីស្វែងរកកសិករដែលមានចំណាប់អារម្មណ៍ចំពោះ PSG |
| ១២-១៣/០៩/១៧ | បញ្ចូលទិន្នន័យនៃការធ្វើផែនការរបស់សមាជិក |
| ១៤/០៩/១៧ | ធ្វើការវិភាគទិន្នន័យនៃការធ្វើផែនការរបស់សមាជិក |
| ១៤/០៩/១៧ | ពិភាក្សាជាមួយនាយក ISC អំពីលទ្ធផលនៃការវិភាគទិន្នន័យ |
| ១៥/០៩/១៧ | រៀបចំឯកសារ និងឧបករណ៍សម្រាប់ការវិវឌ្ឍន៍ PSG និងការជួបប្រជុំជាមួយសមាជិកគណៈកម្មាធិការ FWUC ស្តីពីការជ្រើសរើសអ្នកទិញ |
| ១៦/០៩/១៧ | ធ្វើបច្ចុប្បន្នភាពការធ្វើផែនការរបស់សមាជិកសម្រាប់ PSG |
| ១៧/០៩/១៧ | ដំណើរការនៃការលក់ស្រូវនៅ FWUC |
| ១៨/០៩/១៧ | ដំណើរការនៃការលក់ស្រូវនៅរោងម៉ាស៊ីនកិនស្រូវ និងបន្តធ្វើបច្ចុប្បន្នភាពផែនការ |
| ១៩/០៩/១៧ | ដំណើរការលក់ស្រូវនៅ FWUC និងទទួលមូលប្បទានប័ត្រពីម្ចាស់រោងម៉ាស៊ីនកិនស្រូវ |
| ២០/០៩/១៧ | ដំណើរការនៃការលក់ស្រូវនៅរោងម៉ាស៊ីនកិនស្រូវ និងទទួលមូលប្បទានប័ត្រពីម្ចាស់រោងម៉ាស៊ីនកិនស្រូវ ហើយដកប្រាក់ពីធនាគារ និងបន្តទៅធ្វើបច្ចុប្បន្នភាពផែនការ |
| ២១/០៩/១៧ | រៀបចំប្រាក់សម្រាប់ផ្តល់ជូនដល់សមាជិកសម្រាប់ការទូទាត់ថ្លៃស្រូវឡានទីមួយ |
| ២២/០៩/១៧ | ដកប្រាក់ពីធនាគារ ហើយធ្វើការទូទាត់ថ្លៃស្រូវឡានទីពីរ និងការប្រជុំស្តីពីបទពិសោធន៍ដែលទទួលបានពី PSG ជាមួយសមាជិកគណៈកម្មាធិការ FWUC |

## ឧបសម្ព័ន្ធ ២៖ ការវិភាគថ្លៃចំណាយផលិតកម្មស្រូវ និងប្រាក់ចំណូលសម្រាប់កសិករនៅក្នុង FWUC បារាយណ៍ សម្រាប់ការប្រមូលផលស្រូវសែនក្រអូបនាឆ្នាំ ២០១៦ (ផ្អែកលើការលក់ទៅឱ្យអ្នកប្រមូលទិញក្នុងស្រុក)

ផ្អែកលើបទសម្ភាសន៍របស់កសិករអំពីផលិតកម្មស្រូវសែនក្រអូបក្នុងតំបន់ស្រោចស្រពរបស់ FWUC បារាយណ៍ ពួកគាត់បាននិយាយថា ទិន្នផលជាមធ្យមគឺ ៣ តោនក្នុងមួយហិកតា ។ តម្លៃមធ្យមគឺ ៧៣០ រៀល ក្នុងមួយគីឡូក្រាមសម្រាប់ស្រូវសើម។ ប្រាក់ចំណូលសរុបគឺ ៥៤៧.៥០ ដុល្លារអាមេរិកក្នុងមួយហិកតា (ដោយ យើងយក ៣,០០០ គីឡូក្រាមគុណនឹង ៧៣០ រៀល ហើយចែកនឹង ៤.០០០ រៀល) ។

ថ្លៃចំណាយផលិតកម្មសម្រាប់ការផលិតពូជស្រូវសែនក្រអូបគឺ ៤២១.៨៨ ដុល្លារអាមេរិកក្នុងមួយហិកតា ។

ដូច្នេះប្រាក់ចំណេញរបស់កសិករធម្មតាសម្រាប់ផលិតកម្មពូជស្រូវសែនក្រអូបគឺ ១២៥.៦៣ ដុល្លារអាមេរិកក្នុងមួយហិកតាសម្រាប់មួយវដ្ត (ប្រហែល ១០៥ ថ្ងៃ) ឬ ២៩.៧៨ % នៃថ្លៃចំណាយផលិតកម្ម ។

**លទ្ធផលសេដ្ឋកិច្ចនៃផលិតកម្មស្រូវនៅ FWUC បារាយណ៍ សម្រាប់ពូជស្រូវសែនក្រអូប ក្នុងឆ្នាំ ២០១៦ និងនៅពេលលក់នៅមាត់ទ្វារកសិដ្ឋានទៅឱ្យអ្នកប្រមូលទិញក្នុងស្រុក (សម្រាប់មួយហិកតា)**

| | | | |
|---|---|---|---|
| **I.** | **ប្រាក់ចំណូលក្នុងមួយហិកតាសម្រាប់មួយវដ្ត គិតជាដុល្លារអាមេរិក** | | **៥៤៧.៥០ $** |
| ១.១. | ទិន្នផលមធ្យម សែនក្រអូប (៣ តោនក្នុងមួយហិកតា x ៧៣០ រៀល) | ៥៤៧.៥០ $ | |
| **II.** | **ថ្លៃចំណាយផលិតកម្មក្នុងមួយហិកតាសម្រាប់មួយវដ្តគិតជាដុល្លារអាមេរិក** | | **៤២១.៨៨ $** |
| ២.១. | ពូជ *សែនក្រអូប* (១៨០ គ.ក) | ១៣៥.០០ $ | |
| ២.២. | ភ្ជួររាស់ (២ លើក) | ៦៥.០០$ | |
| ២.៣. | ថ្នាំសម្លាប់សត្វល្អិត (១ លើក) | ២០.០០ $ | |
| ២.៤. | ជី | ១១២.៥០ $ | |
| ២.៥. | ថ្លៃពលកម្ម | ២៥.០០ $ | |
| ២.៦. | ម៉ាស៊ីនច្រូត | ៦២.៥០ $ | |
| ២.៧. | ថ្លៃសេវាស្រោចស្រព (១៥.០០០ ៛/ហិកតា/ឆ្នាំ/២ វដ្ត) | ១.៨៨ $ | |
| **III.** | **ប្រាក់ចំណេញក្នុងមួយហិកតាសម្រាប់មួយវដ្តគិតជាដុល្លារអាមេរិក** | | **១២៥.៦៣ $** |